ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

## សារជូនពរ

### ផ្ញើជូន

### នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ
### ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី ៦៨ ទិវាកំណើតកងយោធពលខេមរភូមិន្ទ
### ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ - ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១

**មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហាន គ្រប់ស្ថាប័ន កងឯកភាព នៃកងយោធពលខេមរភូមិន្ទ ជាទីស្នេហា !**

ក្នុងឱកាសប្រកបដោយមហានក្ខត្តឫក្សដ៏ឧត្តុង្គឧត្តម នៃពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៦៨ ទិវាកំណើតកងយោធពលខេមរភូមិន្ទ និងស្របជាមួយទិវាបុណ្យឯករាជ្យជាតិ **ថ្ងៃទី០៩ នៃវិច្ឆិកា ឆ្នាំ១៩៥៣-ថ្ងៃទី០៩នៃវិច្ឆិកា ឆ្នាំ២០២១**នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្ញុំផ្ទាល់ សូមផ្ញើជូននូវការសាកសួរសុខទុក្ខ ដោយក្តីនឹករលឹក និងជាទីស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅបំផុត ចំពោះនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ដែលកំពុងបំពេញភារកិច្ចនៅតាមស្ថាប័ន កងឯកភាពនានា ក៏ដូចជាសិក្ខាកាមកំពុងសិក្សាជំនាញផ្សេងៗនៅបណ្តាប្រទេសជាមិត្តមួយចំនួន ព្រមទាំងកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។ សូមជូននូវសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខ សូមទទួលបាននូវសុខភាពល្អ កម្លាំងពលំមាំមួន ចៀសផុតអំពីជំងឺរាតត្បាតកូវីដ-១៩ ដ៏កាចសាហាវ ដែលបាននិងកំពុងគំរាមកំហែងនៅទូទាំងពិភពលោក ហើយកងយោធពលខេមរភូមិន្ទយើងក៏កំពុងតែបានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការបង្ការទប់ស្កាត់ ការពារ និងសង្គ្រោះប្រជាពលរដ្ឋជនរួមជាតិទាំងអស់ ឱ្យរួចផុតពីគ្រោះនៃការឆ្លងរាលដាលពីជំងឺកូវីដ-១៩ដ៏កាចសាហាវនេះផងដែរ។

ក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរយ៉ាងស្មោះ ចំពោះជោគជ័យដ៏ត្រចះត្រចង់នៃសមិទ្ធផលដ៏ធំធេងក្នុងឆ្នាំកន្លងមក ក្នុងកិច្ចការពារជាតិមាតុភូមិ ការពារសន្តិសុខជាតិ ថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ និងភាពសុខក្សេមក្សាន្តរបស់ប្រជាជន ពិសេសកងយោធពលខេមរភូមិន្ទ បានសកម្មអនុវត្ត យុទ្ធនាការជាតិចាក់វ៉ាក់សាំងជូនយោធិន នគបាល មន្ត្រី កីឡាករ កីឡាការិនី និយោជិក ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងបណ្តាខេត្តមួយចំនួនតាមការប្រគល់ភារកិច្ចរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធិភាព និងទទួលខុសត្រូវខ្ពស់។ ម្យ៉ាងទៀត កងយោធពលខេមរភូមិន្ទយើងបានចូលរួមអនុវត្តប្រកបដោយជោគជ័យនូវភារកិច្ចអន្តរជាតិ លើវិស័យមនុស្សធម៌ បំពេញបេសកកម្មជាកងកម្លាំងរក្សាសន្តិភាព ក្រោមឆត្ររបស់អង្គការសហប្រជាជាតិ ដើម្បីបុព្វហេតុសន្តិភាពនិងកិច្ចសហប្រតិបត្តិការអន្តរជាតិល្អ ដែលជាក្តីមោទនភាព និងជាកិត្តិយសដ៏ខ្ពង់ខ្ពស់ឧត្តុង្គឧត្តមរបស់កងយោធពល-ខេមរភូមិន្ទ ក៏ដូចជាប្រជាជាតិកម្ពុជាយើងទាំងមូលដែលមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រពីមុនមក ធ្វើឱ្យកិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជា កាន់តែល្បីរន្ទឺនៅលើឆាកអន្តរជាតិ។

ទីចាត់ការនីតិកម្ម សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២៧៩: generalsec@mod.gov.kh

សរុបមកវិញ រាល់សមិទ្ធផលដ៏ធំធេងដែលសម្រេចបានកន្លងមកនេះ គឺអាស្រ័យដោយការខិតខំប្រឹងប្រែងតស៊ូលះបង់ពុំខ្លាចនឿយហត់ និងការធ្វើពលិកម្មគ្រប់បែបយ៉ាង គួបផ្សំជាមួយនិងស្មារតីទទួលខុសត្រូវខ្ពស់ របស់ថ្នាក់ដឹកនាំគ្រប់ស្ថាប័ន កងឯកភាព ក្នុងការចាត់តាំងអនុវត្តការងារជាក់ស្តែង។

**មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហាន គ្រប់ស្ថាប័ន កងឯកភាព នៃកងយោធពលខេមរភូមិន្ទ ជាទីស្នេហា** !

ក្នុងឱកាសដ៏ឧត្តុង្គឧត្តម នៃទិវារំលឹកខួបអនុស្សាវរីយ៍លើកទី**៦៨** ទិវាកំណើតកងយោធពលខេមរភូមិន្ទ និងព្រមជាមួយទិវាបុណ្យឯករាជ្យជាតិ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្នុងនាមខ្ញុំផ្ទាល់ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្ទសាធុការពរជ័យសិរីមង្គល មហាប្រសើរជូនចំពោះ នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេ-មរភូមិន្ទ សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ អាយុយឺនយូរ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ច ជូនជាតិមាតុភូមិ។

សូមផ្ញើជូននូវការសួរសុខទុក្ខដល់យោធិន **ជំងឺ របួស ពិការ** ដែលកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យនានា សូមឱ្យបានឆាប់ជាសះស្បើយពីជំងឺ មានសុខភាពល្អបរិបូរណ៍ កម្លាំងរឹងមាំ និងប្រកបដោយសេចក្តីសុខគ្រប់ពេលវេលា និងសូមជូនពរដល់អតីតយុទ្ធជន ព្រមទាំងក្រុមគ្រួសារដែលកំពុងរស់នៅក្នុងសង្គមស៊ីវិល សូមមានជីវភាពរស់នៅធូរធានិងប្រកបដោយសុភមង្គលរុងរឿង។

សូមផ្ញើជូន មេបញ្ជាការ មេបញ្ជាការរង គ្រប់ស្ថាប័ន កងឯកភាព នាយទាហាន នាយទាហានរង និងពល-ទាហាន ក្នុងកងយោធពលខេមភូមិន្ទ ទាំងសិក្ខាកាមដែលកំពុងបំពេញការសិក្សាជំនាញផ្សេងៗ នៅតាមបណ្តាប្រទេសជាមិត្ត រួមទាំងកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាពក្រោមកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់អង្គការសហប្រជាជាតិ ព្រមទាំងក្រុមគ្រួសារ ត្រូវអនុវត្តឱ្យបានតាមការណែនាំរបស់រាជរដ្ឋាភិបាល និងប្រកាន់ខ្ជាប់នូវវិធានការការពារនានារបស់ក្រសួងសុខាភិបាល គឺត្រូវពាក់ម៉ាស់ លាងដៃជាមួយសាប៊ូ អាកុល ឬជែល រក្សាគម្លាតសុវត្ថិភាព ដើម្បីបង្ការទប់ស្កាត់ និងការពារឱ្យរួចផុតពីគ្រោះនៃការឆ្លងរាលដាលពីជំងឺកូវីដ-១៩ដ៏កាចសាហាវនេះ ព្រមទាំងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** ជានិច្ចនិរន្តរ៍តរៀងទៅ។

ថ្ងៃពុធ ១៣រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០២១
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**